ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ..០៤៥៥...ផ....អបាស/ក្រសបាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០០៨

រដ្ឋមន្ត្រី ក្រសួងសុខាភិបាល

ជម្រាបមក

លោកប្រធានគ្រឹះស្ថាននាំចូល និងនាំចេញឱសថ OCEAN Pharma

**កម្មវត្ថុ** : ករណី Amoxicillin 500 mg B/10 Blisters x 10 Capsules មានសារជាតិសកម្មមិនគ្រប់គ្រាន់ ។

តបតាមកម្មវត្ថុខាងលើនេះ ខ្ញុំសូមជម្រាបលោកប្រធានថា : ក្រសួងសុខាភិបាលបានស្រាវជ្រាវឃើញថាឱសថ Amoxicillin 500mg B/10 Blister x 10 Capsules ដែលមានលេខឡូតិ៍ 0329 ខែឆ្នាំផលិត 05-2008 ខែឆ្នាំផុតកំណត់ 05-2011 និងមានលេខបញ្ជិកា CAM 798-07 ផលិតដោយរោងចក្រផលិតឱសថនៅប្រទេសចិន ឈ្មោះ SHIJIAZHUANG OUYI PHARMACEUTICAL ដែលក្រុមហ៊ុន OCEAN Pharma របស់លោកបាន នាំចូល និង ចែកចាយ ក្នុងព្រះរាជាណាចក្រកម្ពុជាកន្លងមក មានសារជាតិសកម្មត្រឹមតែ 49,07 % តែប៉ុណ្ណោះ ។

ក្រសួងសុខាភិបាលបានសម្រេចដកឱសថ Amoxicillin 500 mg នេះ ចេញពីបញ្ជិកាឱសថរបស់ក្រសួងសុខាភិបាល ហើយក្រសួងសូមឱ្យលោកប្រធានបញ្ឈប់ការនាំចូល ការចែកចាយ និងចាត់ចែងប្រមូលមុខឱសថនេះឱ្យអស់ពីទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជាជាបន្ទាន់ ហើយធ្វើរបាយការណ៍ផ្ញើមកនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង ។

ក្នុងករណីមានឱសថផ្សេងទៀតដែលក្រុមហ៊ុនលោកនាំចូលមកមានបញ្ហាគុណភាពដូចគ្នានេះ ក្រសួងសុខាភិបាលនឹងធ្វើការបញ្ឈប់ក្រុមហ៊ុន OCEAN Pharma មិនឱ្យបន្តអាជីវកម្មឱសថតទៅទៀតបានទេ ។ ដោយឡែករោងចក្រផលិតដែលបានបញ្ជូនឱសថគ្មានគុណភាពមកទីផ្សារកម្ពុជាក៏នឹងត្រូវហាមឃាត់ជាស្ថាពរ លែងឱ្យធ្វើអាជីវកម្មផលិតផលរបស់ខ្លួនលើទីផ្សារកម្ពុជាផងដែរ ។

សូមលោកប្រធានជ្រាប និងចាត់ចែងតាមសំណូមពររបស់ក្រសួងសុខាភិបាលឱ្យមានប្រសិទ្ធភាព ។

**ចម្លងជូន :**

- ខុទ្ទកាល័យក្រសួងសុខាភិបាល
- អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
- នាយកដ្ឋានឱសថ-ចំណីអាហារ-បរិក្ខារពេទ្យ និងគ្រឿងសំអាង
- គ្រប់មន្ទីរសុខាភិបាលរាជធានី-ខេត្ត
- គ្រប់ក្រុមហ៊ុនអាហរ័ណ-នីហរ័ណឱសថ
- គ្រប់សហគ្រាសផលិតឱសថ
- គ្រប់ឱសថស្ថាន-ឱសថស្ថានរង
- ឯកសារ - កាលប្បវត្តិ

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ឱសថការី ជួ-យិនស៊ីម

573